*ឧបសម្ព័ន្ធទី២-ខ នៃប្រកាសលេខ២៤៩ ក.ប/ប្រ.ក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦*

*សម្រាប់សមាគមនិយោជក*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# លក្ខន្តិកៈ

# នៃ

# សមាគមនិយោជក/សហព័ន្ធនិយោជក

# ឈ្មោះ...................................

**ឆ្នាំ..............**

# មាតិកា

ទំព័រ


សេចក្តីថ្លែងការណ៍ស្តីពីគោលបំណងរបស់សមាគមនិយោជក/សហព័ន្ធនិយោជក..........

ជំពូកទី១ ឈ្មោះ អាសយដ្ឋាន តំរូសញ្ញា និងតំរូត្រា

ប្រការ១..........

ប្រការ២..........

ប្រការ៣..........

ប្រការ៤..........

ជំពូកទី២ គោលដៅ និងដែនអនុវត្ត

ប្រការ៥..........

ប្រការ៦..........

ជំពូកទី៣ រចនាសម្ព័ន្ធ និងតួនាទីភារកិច្ច

ប្រការ៧..........

ប្រការ៨..........

ជំពូកទី៤ សមាជិកភាព

ប្រការ៩..........

ប្រការ១០..........

ប្រការ១១..........

ប្រការ១២..........

ជំពូកទី៥ សិទ្ធិ និងករណីយកិច្ចរបស់សមាជិក

ប្រការ១៣..........

ប្រការ១៤..........

ជំពូកទី៦ ហិរញ្ញវត្ថុរបស់សមាគមនិយោជក/សហព័ន្ធនិយោជក

ប្រការ១៥..........

ប្រការ១៦..........

ប្រការ១៧..........

ប្រការ១៨..........

ប្រការ១៩..........

ជំពូកទី៧ ការថែរក្សាកំណត់ត្រាហិរញ្ញវត្ថុ របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាពប្រចាំឆ្នាំ

ប្រការ២០..........

ប្រការ២១..........

ជំពូកទី៨ សន្និបាត

ប្រការ២២..........

ជំពូកទី៩ ការរៀបចំបទបញ្ជាផ្ទៃក្នុងរដ្ឋបាល ការកែប្រែលក្ខន្តិកៈ និងការរំលាយ

ប្រការ២៣..........

ប្រការ២៤..........

ប្រការ២៥..........

ជំពូកទី១០ ឡុកអៅ
ប្រការ២៦..........
ប្រការ២៧..........
ជំពូកទី១១ អ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាល
ប្រការ២៨..........
ប្រការ២៩..........
ជំពូកទី១២ អន្តរប្បញ្ញត្តិ
ប្រការ៣០..........
ជំពូកទី១៣ អវសានប្បញ្ញត្តិ
ប្រការ៣១..........

# សេចក្តីថ្លែងការណ៍ស្តីពីគោលបំណងរបស់សមាគមនិយោជក/សហព័ន្ធនិយោជក

សមាគមនិយោជក/សហព័ន្ធនិយោជក ត្រូវបានបង្កើតឡើងដោយការរួបរួមនៃនិយោជក/សមាគមនិយោជក ចំនួន......... *(យ៉ាងតិចចំនួន៩សម្រាប់សមាគមនិយោជក ឬ យ៉ាងតិច៦សម្រាប់សហព័ន្ធនិយោជក)* ក្នុងគោលបំណង......។ សមាគមនិយោជក/សហព័ន្ធនិយោជក មិនចូលរួមធ្វើសកម្មភាពនយោបាយ និងមិនបម្រើនិន្នាការនយោបាយណាមួយឡើយ។

......................................

ធ្វើនៅ....... ថ្ងៃទី....... ខែ....... ឆ្នាំ២០១៦

| ឈ្មោះនិយោជក/សហព័ន្ធនិយោជក | ឈ្មោះប្រធាន | ហត្ថលេខា |
|---|---|---|
| ១. | | |
| ២. | | |
| ៣. | | |
| ៤. | | |
| ៥. | | |
| ៦. | | |
| ៧. | | |
| ៨. | | |
| ៩. | | |

## ជំពូកទី១
## ឈ្មោះ អាសយដ្ឋាន តំរូសញ្ញា និងតំរូត្រា

**ប្រការ១ .._** *(ឈ្មោះ និងឈ្មោះជាអក្សរកាត់)*

សមាគមនិយោជក/សហព័ន្ធនិយោជកមានឈ្មោះជាភាសាខ្មែរ.................. ដែលហៅកាត់ថា............... និងមានឈ្មោះជាភាសាអង់គ្លេស............. ដែលហៅកាត់ថា...........។

**ប្រការ២ .._** *(អាសយដ្ឋាន)*

សមាគមនិយោជក/សហព័ន្ធនិយោជក...................... មានអាសយដ្ឋាននៅផ្ទះលេខ...... ផ្លូវ............. ភូមិ ............... ឃុំ/សង្កាត់.................. ស្រុក/ខណ្ឌ/ក្រុង............ រាជធានី/ខេត្ត...........................។

**ប្រការ៣ .._** *(តំរូសញ្ញា)*

សមាគមនិយោជក/សហព័ន្ធនិយោជក.............................. មានតំរូសញ្ញាដូចតទៅ៖
*(សូមភ្ជាប់រូបសញ្ញានៅទីនេះ)*

- រូបសញ្ញានេះមាន *(បរិយាយទម្រង់ និងរូបដែលប្រើក្នុងរូបសញ្ញា)*
  - ...............................
  - ..............................
  - .......................................
- អត្ថន័យនៃរូបសញ្ញា
  - រូប................. តំណាងឱ្យ............................
  - ពណ៌............. តំណាងឱ្យ...................
  - ...........................................................

**ប្រការ៤ .._** *(តំរូត្រា)*

សមាគមនិយោជក/សហព័ន្ធនិយោជកមានត្រាដូចខាងក្រោម៖
*(សូមប្រថាប់តំរូត្រានៅទីនេះ)*

## ជំពូកទី២
## គោលដៅ និងដែនអនុវត្ត

**ប្រការ៥ .._** *(គោលដៅ)*

សមាគមនិយោជក/សហព័ន្ធនិយោជក................................មានគោលបំណង និងគោលដៅដូចខាងក្រោម៖

- ការពារ និងគោរពសិទ្ធិសេរីភាព និងផលប្រយោជន៍របស់សមាជិក
- ផ្តល់ប្រឹក្សាយោបល់ដល់សមាជិក
- ចូលរួមចំណែកធ្វើឱ្យមានសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ
- មិនចូលរួមធ្វើសកម្មភាពនយោបាយ ឬបម្រើនិន្នាការនយោបាយណាមួយ
- ........................................................................................ ។

**ប្រការ៦ .._** *(ដែនអនុវត្ត)*

សមាគមនិយោជក/សហព័ន្ធនិយោជក............................... មានដែនអនុវត្ត..............................។

## ជំពូកទី៣
## រចនាសម្ព័ន្ធ និងតួនាទីភារកិច្ច

**ប្រការ៧ ._** *(រចនាសម្ព័ន្ធ)*

សមាគមនិយោជក/សហព័ន្ធនិយោជក..................... មានរចនាសម្ព័ន្ធដូចខាងក្រោម៖

- ប្រធាន
- អនុប្រធាន
- លេខាធិការ/អគ្គលេខាធិការ
- ហេរញ្ញិក/អគ្គហេរញ្ញិក
- ........................

**ប្រការ៨ ._** *(តួនាទី និងភារកិច្ច)*

ប្រធានមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ...............................................។

អនុប្រធានមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ...............................................។

លេខាធិការ/អគ្គលេខាធិការមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ...............................................។

ហេរញ្ញិក/អគ្គហេរញ្ញិកមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ...............................................។

..............................................................................។

## ជំពូកទី៤
## សមាជិកភាព

**ប្រការ៩ ._** *(លក្ខខណ្ឌនៃការចូលជាសមាជិក)*

*(សម្រាប់សមាគមនិយោជក)* ដើម្បីចូលជាសមាជិកនៃសមាគមនិយោជក.............................................. និយោជកត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ដាក់លិខិតសុំចូលជាសមាជិក
- បង់ប្រាក់ភាគទានចំនួន.....រៀលក្នុងមួយខែ/ឆ្នាំ ទៅគណនីធនាគាររបស់សមាគមនិយោជក
- ..................................................................

*(សម្រាប់សហព័ន្ធនិយោជក)* ដើម្បីចូលជាសមាជិកនៃសហព័ន្ធនិយោជក............................................. សមាគមនិយោជកត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ដាក់លិខិតសុំចូលជាសមាជិកដែលបានចុះហត្ថលេខា ឬផ្តិតស្រាមដៃដោយថ្នាក់ដឹកនាំគ្រប់គ្រងសមាគមនិយោជក ទៅសហព័ន្ធនិយោជក ក្រោយពីទទួលបានការសម្រេចយល់ព្រមឱ្យចូលពីនិយោជកដែលជាសមាជិករបស់សមាគមនិយោជក តាមរយៈការបោះឆ្នោតយល់ព្រមដោយសំឡេងភាគច្រើនដាច់ខាត ស្របតាមលក្ខន្តិកៈរបស់សមាគមនិយោជកនីមួយៗ
- បានរៀបរាប់អំពីកាតព្វកិច្ចនៃនិយោជក ដែលជាសមាជិកសមាគមនិយោជករបស់ខ្លួន មានចំពោះសហព័ន្ធនិយោជក ជាអាទិ៍ កាតព្វកិច្ចបង់ប្រាក់ភាគទានប្រចាំខែ/ឆ្នាំបន្ថែមដែលត្រូវបង់ទៅគណនីធនាគាររបស់សហព័ន្ធនិយោជក អាណត្តិរបស់ថ្នាក់ដឹកនាំសហព័ន្ធនិយោជក....
- ..................................................................

**ប្រការ១០ ._** *(ការដកខ្លួនចេញពីសមាគមនិយោជក/សហព័ន្ធនិយោជក)*

និយោជកមានសិទ្ធិចាកចេញពីសមាគមនិយោជក តាមរយៈការដាក់លិខិតជូនសមាគមនិយោជក។ *(សម្រាប់កម្រិតសមាគមនិយោជក)*

សមាគមនិយោជកមានសិទ្ធិចាកចេញពីសហព័ន្ធនិយោជក តាមរយៈការដាក់លិខិតដែលបានចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយថ្នាក់ដឹកនាំគ្រប់គ្រងសមាគមនិយោជក ទៅសហព័ន្ធនិយោជក ក្រោយពីទទួលបានការសម្រេចយល់ព្រមឱ្យចេញពីនិយោជកដែលជាសមាជិករបស់សមាគមនិយោជក តាមរយៈការបោះឆ្នោតយល់ព្រមដោយសំឡេងភាគច្រើនដាច់ខាត ស្របតាមលក្ខន្តិកៈរបស់សមាគមនិយោជកនីមួយៗ។*(សម្រាប់កម្រិតសហព័ន្ធនិយោជក)*

គ្មានបុគ្គលណាអាចរារាំងដល់សមាជិករបស់សមាគមនិយោជក/សហព័ន្ធនិយោជក ក្នុងការសម្រេចចិត្តដកខ្លួនចេញពីសមាគមនិយោជក/សហព័ន្ធនិយោជកបានឡើយ។

**ប្រការ១១ ._** *(ការបាត់បង់សមាជិកភាព)*

សមាជិកណាមួយនៃសមាគមនិយោជក/សហព័ន្ធនិយោជក.................... ត្រូវបានបាត់បង់សមាជិកភាពក្នុងករណីដូចខាងក្រោម៖

- ការសុំចេញពីសមាគមនិយោជក/សហ័ពន្ធនិយោជក
- សហគ្រាសត្រូវបានបិទលែងដំណើរការជាស្ថាពរ ឬសមាគមនិយោជកត្រូវបានរំលាយ
- ការខកខានក្នុងការបង់ប្រាក់ភាគទានចំនួន....ខែ/ឆ្នាំ
- ...................................................................................

**ប្រការ១២ ._** *(វិន័យ និងទណ្ឌកម្ម)*

..................................................................................................

## ជំពូកទី៥
## សិទ្ធិ និងករណីយកិច្ចរបស់សមាជិក

**ប្រការ១៣ ._** *(សិទ្ធិរបស់សមាជិក)*

សិទ្ធិរបស់សមាជិកសមាគមនិយោជក/សហព័ន្ធនិយោជក មានជាអាទិ៍៖

- ឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំគ្រប់គ្រង
- បោះឆ្នោតជាសម្ងាត់ក្នុងការសម្រេចកែប្រែលក្ខន្តិកៈ និងជ្រើសរើសអ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាល
- ..........................................................
- អនុវត្តនូវសិទ្ធិដទៃផ្សេងទៀតដែលចាំបាច់សម្រាប់ការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួន។

**ប្រការ១៤ ._** *(ករណីយកិច្ចរបស់សមាជិក)*

សមាជិកនៃសមាគមនិយោជក/សហព័ន្ធនិយោជកមានករណីយកិច្ចជាអាទិ៍៖

- គោរពច្បាប់ និងបទប្បញ្ញត្តិទាំងឡាយដែលមានជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា
- គោរពលក្ខន្តិកៈរបស់សមាគមនិយោជក/សហព័ន្ធនិយោជក
- បង់ប្រាក់ភាគទាន
- ..........................................................។

## ជំពូកទី៦
## ហិរញ្ញវត្ថុរបស់សមាគមនិយោជក/សហព័ន្ធនិយោជក

**ប្រការ១៥ ._** *(ប្រភពធនធាន និងហិរញ្ញវត្ថុ)*

ប្រភពធនធាន និងហិរញ្ញវត្ថុរបស់សមាគមនិយោជក/សហព័ន្ធនិយោជកបានមកពី៖

- ភាគទានពីសមាជិកយ៉ាងតិចចំនួន....... រៀល ក្នុងមួយខែ/ឆ្នាំ
- ចំណូលដែលបានមកពីសកម្មភាពរកប្រាក់ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហជីព
- អំណោយ និងជំនួយធនធានហិរញ្ញវត្ថុដែលទទួលបានដោយស្របច្បាប់។

សមាគមនិយោជក/សហព័ន្ធនិយោជកមានគណនីធនាគារលេខ ........................................................ នៅធនាគារ.........................................................។ រាល់ថវិការបស់សមាគមនិយោជក/សហព័ន្ធនិយោជក ជារូបិយបណ្ណ ឬមូលទានបត្រ នឹងរក្សាទុកនៅក្នុងគណនីធនាគារនេះ។

**ប្រការ១៦ ..** *(របៀបនៃការកំណត់ចំនួនប្រាក់ភាគទាន និងការបង់ប្រាក់ភាគទានប្រចាំខែ)*

ចំនួនប្រាក់ភាគទានសមាជិកភាពដែលសមាជិកត្រូវបង់ជូនទៅសមាគមនិយោជក/សហព័ន្ធនិយោជក ត្រូវកំណត់ដោយមហាសន្និបាត ឬសន្និបាតរបស់សមាគមនិយោជក/សហព័ន្ធនិយោជក។

សមាជិកសមាគមនិយោជក/សហព័ន្ធនិយោជក ត្រូវបង់ប្រាក់ភាគទានចំនួន.......រៀលក្នុងមួយខែ/ឆ្នាំ ជាស្វ័យប្រវត្តិទៅគណនីធនាគាររបស់សមាគមនិយោជក/សហព័ន្ធនិយោជក លេខ.................................................................................នៅធនាគារ..................................................................។

**ប្រការ១៧ ..** *(វិយោគកម្មនៃហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិ)*

សមាគមនិយោជក/សហព័ន្ធនិយោជកមានគណនីធនាគារ និងទ្រព្យសម្បត្តិដាច់ដោយឡែក ផ្សេងពីអ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាល។

**ប្រការ១៨ ..** *(ការប្រើប្រាស់ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ)*

ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិដែលសមាគមនិយោជក/សហព័ន្ធនិយោជកមាន គឺប្រើប្រាស់សម្រាប់តែបម្រើឱ្យផលប្រយោជន៍របស់សមាគមនិយោជក/សហព័ន្ធនិយោកតែប៉ុណ្ណោះ។

ការប្រើប្រាស់ហិរញ្ញវត្ថុមានដូចខាងក្រោម៖

- ចំណាយប្រចាំថ្ងៃ ដូចជាសម្ភារការិយាល័យ ទឹក ភ្លើង និងការទំនាក់ទំនង
- ចំណាយលើការជួលទីស្នាក់ការ មធ្យោបាយ ប្រតិបត្តិការ
- ចំណាយលើការអប់រំបណ្តុះបណ្តាលស្តីពីចំណេះដឹងផ្នែកច្បាប់ និងវិជ្ជាជីវៈ
- ចំណាយលើសេវាប្រឹក្សាផ្នែកច្បាប់ និងការអនុវត្តជាក់ស្តែងដល់សមាជិករបស់ខ្លួន
- .......................................................

សមាជិកមានសិទ្ធិស្នើសុំការពន្យល់បង្ហាញ ពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សមាគមនិយោជក/សហព័ន្ធនិយោជក។

**ប្រការ១៩ ..** *(ការចាត់ចែងទ្រព្យសម្បត្តិ នៅពេលរំលាយ)*

ក្នុងករណីដែលសមាគមនិយោជក/សហព័ន្ធនិយោជកត្រូវបានរំលាយ ស្របទៅតាមលក្ខន្តិកៈ ឬបទប្បញ្ញត្តិជាធរមាន ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សមាគមនិយោជក/សហព័ន្ធនិយោជកត្រូវបែងចែកដូចខាងក្រោម៖

- ធ្វើជាអំណោយទៅឱ្យសមាគមនិយោជក/សហព័ន្ធនិយោជក ដែលមានសកម្មភាពដូចគ្នា ឬប្រហាក់ប្រហែល
- ..............................................................

## ជំពូកទី៧
## ការថែរក្សាកំណត់ត្រាហិរញ្ញវត្ថុ
## របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាពប្រចាំឆ្នាំ

**ប្រការ២០ ..** *(ការថែរក្សាកំណត់ត្រាហិរញ្ញវត្ថុ)*

អគ្គហេរញ្ញិកមានករណីយកិច្ចរក្សាទុកនូវវិក្កយបត្រ សក្ខីបត្រ របាយការណ៍ធនាគារ ដើម្បីកត់ត្រាចូលកំណត់ត្រាហិរញ្ញវត្ថុប្រចាំថ្ងៃ និងធ្វើសៀវភៅហិរញ្ញវត្ថុប្រចាំខែ ឆ្នាំ ស្របទៅតាមទម្រង់បែបបទដែលកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

សៀវភៅហិរញ្ញវត្ថុ និងកំណត់ត្រាហិរញ្ញវត្ថុត្រូវរក្សាទុកនៅទីស្នាក់ការរបស់សមាគមនិយោជក/សហព័ន្ធនិយោជក.............................. ដែលមានអាសយដ្ឋានផ្ទះលេខ....... ផ្លូវ........... ភូមិ........... ឃុំ/សង្កាត់................ ស្រុក/ខណ្ឌ/ក្រុង........................ រាជធានី/ខេត្ត........................។

**ប្រការ២១ ..** *(របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាពប្រចាំឆ្នាំ)*

អគ្គលេខាធិការ និងអគ្គហេរញ្ញិក ត្រូវសហការគ្នាធ្វើរបាយការណ៍សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដោយផ្អែកលើកំណត់ត្រាហិរញ្ញវត្ថុប្រចាំថ្ងៃ និងសៀវភៅហិរញ្ញវត្ថុប្រចាំខែ ដើម្បីបង្ហាញជូនដល់សមាជិករបស់ខ្លួនជ្រាប និងចម្លងជូនអង្គភាពទទួលចុះបញ្ជីចំនួន១(មួយ)ច្បាប់ យ៉ាងយូរត្រឹមដំណាច់ខែមីនានៃឆ្នាំបន្ទាប់។

សមាគមនិយោជក/សហព័ន្ធនិយោជកត្រូវបោះពុម្ពផ្សាយជាប្រចាំនូវរបាយការណ៍ប្រចាំឆ្នាំអំពីស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន។

..........................................................................................

## ជំពូកទី៨
## សន្និបាត

**ប្រការ២២ ..** *(សន្និបាត)*

មហាសន្និបាតគឺជាអង្គការចាត់តាំងខ្ពស់បំផុតរបស់សមាគមនិយោជក/សហព័ន្ធនិយោជក ដែលធ្វើឡើងជារៀងរាល់..........ឆ្នាំម្តង។ សន្និបាតប្រចាំឆ្នាំត្រូវធ្វើឡើងជារៀងរាល់១(មួយ)ឆ្នាំម្តង។

ប្រធានមហាសន្និបាត ឬសន្និបាតរាយការណ៍ជូនអង្គមហាសន្និបាត ឬសន្និបាត នូវរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាពប្រចាំឆ្នាំ ឬប្រចាំអាណត្តិរបស់ខ្លួន ដើម្បីឱ្យសមាជិកមហាសន្និបាត ឬសន្និបាតពិនិត្យអនុម័ត។

សមាជិកមានសិទ្ធិបញ្ចេញមតិយោបល់ លើកសំណូមពរ និងសំណួរជូនអង្គមហាសន្និបាត ឬសន្និបាត ដើម្បីពិនិត្យពិភាក្សា និងអនុម័ត។

កូរ៉ុមសម្រាប់ដំណើរការមហាសន្និបាត ត្រូវស្មើនឹង៥០%+១ (ហាសិបភាគរយបូកមួយ) នៃចំនួនសមាជិកសរុបរបស់សមាគមនិយោជក/សហព័ន្ធនិយោជក។ រាល់សេចក្តីសម្រេចនៅក្នុងមហាសន្និបាត ត្រូវអនុម័តដោយសំឡេង......... *(ចំនួនយ៉ាងតិច៥០%+ ១)* នៃសមាជិកដែលចូលរួមមហាសន្និបាត។

ក្នុងករណីចាំបាច់ មហាសន្និបាតវិសាមញ្ញ ឬសន្និបាតវិសាមញ្ញអាចធ្វើទៅបានតាមការស្នើសុំរបស់សមាជិកចំនួន........ *(យ៉ាងតិច២០%)* នៃចំនួនសមាជិកសរុប។

## ជំពូកទី៩
## ការរៀបចំបទបញ្ជាផ្ទៃក្នុងរដ្ឋបាល ការកែប្រែលក្ខន្តិកៈ និងការរំលាយ

**ប្រការ២៣ ..** *(បទបញ្ជាផ្ទៃក្នុងរដ្ឋបាល)*

បទបញ្ជាផ្ទៃក្នុងរដ្ឋបាលរបស់សមាគមនិយោជក/សហព័ន្ធនិយោជក ..................................................... ត្រូវអនុម័តដោយមហាសន្និបាត ឬសន្និបាត។

**ប្រការ២៤ ..** *(ការកែប្រែលក្ខន្តិកៈ)*

ការកែប្រែលក្ខន្តិកៈសមាគមនិយោជក/សហព័ន្ធនិយោជកអាចធ្វើទៅបាន លុះត្រាតែមានសំណើរបស់សមាជិកសមាគមនិយោជក/សហព័ន្ធនិយោជកចំនួន...... *(ចំនួនយ៉ាងតិច២០%)* នៃចំនួនសមាជិកសរុបរបស់សមាគមនិយោជក/សហព័ន្ធនិយោជក ហើយត្រូវបានអនុម័តដោយមហាសន្និបាត។

**ប្រការ២៥ ..** *(ការរំលាយ)*

សមាគមនិយោជក/សហព័ន្ធនិយោជកអាចត្រូវបានរំលាយតាមវិធីណាមួយ ដូចខាងក្រោម៖

- សមាគមនិយោជក/សហព័ន្ធនិយោជកត្រូវបានរំលាយ តាមរយៈការបោះឆ្នោតសម្រេចដោយសំឡេង ...... *(យ៉ាងតិច៥០%+១)* របស់សមាជិកសមាគមនិយោជក/សហព័ន្ធនិយោជក នៅក្នុងមហាសន្និបាត បន្ទាប់ពីមានសំណើសុំរំលាយពីសមាជិកសមាគមនិយោជក/សហព័ន្ធនិយោជក ចំនួនយ៉ាងតិច៥០% (ហាសិបភាគរយ)។
- សមាគមនិយោជកត្រូវបានរំលាយចោលដោយតុលាការ។

## ជំពូកទី១០
## ឡុកអៅ

**ប្រការ២៦ ..** *(សិទ្ធិធ្វើឡុកអៅ)*

សិទ្ធិធ្វើឡុកអៅ គឺជាសិទ្ធិរបស់សមាជិក ស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

......................

**ប្រការ២៧ ..** *(ការបោះឆ្នោតសម្រេចធ្វើឡុកអៅ)*

ឡុកអៅ ត្រូវសម្រេចដោយនិយោជកដែលជាសមាជិកតាមរយៈការបោះឆ្នោតជាសម្ងាត់។

កម្មវត្ថុនៃការធ្វើឡុកអៅត្រូវអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

នីតិវិធីក្នុងការធ្វើឡុកអៅត្រូវអនុវត្តស្របតាមច្បាប់ស្តីពីការងារ និងបទប្បញ្ញត្តិជាធរមាន សំដៅរក្សាផលប្រយោជន៍របស់សមាជិក និងសណ្តាប់ធ្នាប់សាធារណៈ។

## ជំពូកទី១១
## អ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាល

**ប្រការ២៨ ..** *(លក្ខខណ្ឌសម្រាប់អ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាល )*

អ្នកដឹកនាំគ្រប់គ្រងនិងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សមាគមនិយោជក/សហព័ន្ធនិយោជក ដែលជាពលរដ្ឋខ្មែរ ត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

- មានអាយុយ៉ាងតិច១៨(ដប់ប្រាំបី)ឆ្នាំ
- មិនធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ
- ..........................................................។

អ្នកដឹកនាំគ្រប់គ្រងនិងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សមាគមនិយោជក/សហព័ន្ធនិយោជក ដែលជាជនបរទេស ត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

- មានអាយុយ៉ាងតិច១៨(ដប់ប្រាំបី)ឆ្នាំ
- បាននិងកំពុងវិនិយោគ ឬធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាយ៉ាងតិច ២(ពីរ)ឆ្នាំ
- មិនធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ
- មានសិទ្ធិស្នាក់នៅនិងមានទីលំនៅអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រឹមត្រូវតាមច្បាប់ស្តីពីអន្តោប្រវេសន៍នៃព្រះរាជាណាចក្រកម្ពុជា
- ..............................................។

**ប្រការ២៩ ..** *(ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំ)*

ការបោះឆ្នោតជ្រើសរើសអ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សមាគមនិយោជក/សហព័ន្ធនិយោជក ត្រូវធ្វើឡើងក្នុងមហាសន្និបាត តាមរយៈការបោះឆ្នោតជាសម្ងាត់។

អាណត្តិសម្រាប់មុខតំណែងអ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលមានរយៈពេល.......ឆ្នាំ។ អ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលអាចឈរឈ្មោះបោះឆ្នោតជាថ្មីឡើងវិញបាន។

.......................................................................។

## ជំពូកទី១២
## អន្តរប្បញ្ញត្តិ

**ប្រការ៣០ .-**

.....................................................................................

## ជំពូកទី១៣
## អវសានប្បញ្ញត្តិ

**ប្រការ៣១ .-** *(សុពលភាពអនុវត្ត)*

លក្ខន្តិកៈសមាគមនិយោជក/សហព័ន្ធនិយោជក...................................... ត្រូវបានមហាសន្និបាតអនុម័ត នៅថ្ងៃទី..... ខែ....... ឆ្នាំ......... ដោយសំឡេង...... និងមានសុពលភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើជា... *(យ៉ាងតិច៣ច្បាប់)* នៅ............ ថ្ងៃទី...... ខែ......... ឆ្នាំ............

**ប្រធាន**